# ទំនុកដំកើង ១២៣

អ្នកនិពន្ធ រហ្វ លេភិឡារ

**សេចក្តីណែនាំ ទំនុកដំកើង ១២៣-១២៥។ ក្រុមទីពីរដែលមានទំនុកដំកើងបី។**

សេចក្តីចំអករបស់មនុស្ស (ទំនុកដំកើង ១២៣) និងភាពជាខ្មាំងសត្រូវ (ទំនុកដំកើង ១២៤) នាំឲ្យប្រជារាស្ត្ររបស់ព្រះពឹងផ្អែកលើទ្រង់ទាំងស្រុង (ទំនុកដំកើង ១២៥)។ អស់អ្នកដែលទុកចិត្តដល់ព្រះយ៉ាវេមានសុវត្ថិភាពដូចជាស៊ីយ៉ូន។ តារាងខាងក្រោមបង្ហាញអំពីភាពស្រដៀងគ្នារវាងក្រុមទីមួយដែលមានទំនុកដំកើងបី ១២០-១២២ នឹងក្រុមទីពីរ ១២៣-១២៥។

| | | | |
|---|---|---|---|
| ១២០ | សេចក្តីអង្វរព្រះយ៉ាវេក្នុងការដោះស្រាយជាមួយពួកខ្មាំងសត្រូវ។ | ១២៣ | សេចក្តីអង្វរសុំសេចក្តីមេត្តាករុណាដោយសារតែពួកខ្មាំងសត្រូវ។ |
| ១២១ | កាលៈទេសៈគ្រោះថ្នាក់ | ១២៤ | គ្រោះថ្នាក់ពីអំណាចរបស់មនុស្ស |
| ១២២ | ស៊ីយ៉ូនជានិមិត្តរូបនៃសន្តិភាព | ១២៥ | ស៊ីយ៉ូនជានិមិត្តរូបនៃកំលាំង |

**ខ. ១** *ដែលគង់នៅស្ថានសួគ៌អើយ*។ អ្នកនិពន្ធដឹងថាមានតែព្រះយេហូវ៉ា(ព្រះយ៉ាវេ)ទេដែលជាស្តេចហើយគ្រប់គ្រងលើទាំងអស់។ ទ្រង់ដែលគង់នៅស្ថានសួគ៌ «ធ្វើការដែលគាប់ដល់ព្រះហឫទ័យទ្រង់» (ទំនុកដំកើង ១១៥:៣)។ ខនេះផ្តល់រូបភាពល្អនៃសេចក្តីជំនឿនិងសេចក្តីសង្ឃឹម។ ដោយសារតែទ្រង់គ្រប់គ្រងលើទាំងអស់ នោះវាជាការត្រឹមត្រូវក្នុងការ «ងើបភ្នែកមើល» ទៅឯទ្រង់សំរាប់ជំនួយ។ វាពិតជាការខុសទាំងស្រុងក្នុងការស្វែងរកជំនួយពីរូបព្រះឬពួកវិញ្ញាណ ពីព្រោះព្រះយេហូវ៉ាមានអធិបតីភាព។

**ខ. ២** ឥឡូវនេះមានការប្រៀបធៀបពីរជាមួយទាសាម្នាក់និងទាសីម្នាក់។ នៅក្នុងការប្រៀបធៀបនេះ ទាសានិងទាសីកំពុងស្វែងរកភាពធូរស្រាល មិនមែនស្វែងរកបញ្ហានោះទេ។ អ្នកទាំងនេះគឺជាអ្នកបំរើស្មោះត្រង់ដែលរង់ចាំដោយអត់ធ្មត់។

**ខ. ៣, ៤** *សេចក្តីមើលងាយ* គឺជាទំរង់នៃការបដិសេធយ៉ាងខ្លាំង (ប្រៀបធៀប ម៉ាថាយ ៥:២២)។ តែពេញក្នុងប្រវត្តិសាស្ត្រ ប្រជារាស្ត្ររបស់ព្រះតែងតែបានទទួលសេចក្តីមើលងាយពីលោកិយ។ ការទទួលសេចក្តីមើលងាយពីលោកិយអាចជាកិត្តិយសសំរាប់ប្រជារាស្ត្ររបស់ព្រះ(កិច្ចការ ៥:៤១) ហើយវាគឺជាអ្វីដែលព្រះគ្រីស្ទទ្រង់ផ្ទាល់បានទទួល។ តែថ្វីបើព្រះប្រទានពរដល់យើងហើយវាជាកិត្តិយសក៏ដោយ ក៏វានៅតែពិបាក ដូច្នេះអ្នកនិពន្ធអធិស្ឋានសូមសេចក្តីមេត្តាករុណាដោយសារមានសេចក្តីមើលងាយពីពួកខ្មាំងសត្រូវរបស់ពួកគេ។ ការលើកឡើងដដែលៗរបស់ពាក្យ «ឆ្អែត» និង «យ៉ាងក្រៃលែង» បង្ហាញថា ពួកគេមិនបានទទួលសេចក្តីមើលងាយតិចតួចនោះទេ ប៉ុន្តែទទួលយ៉ាងខ្លាំងអស់រយៈពេលជាយូរមួយ ប៉ុន្តែពួកនៅតែអធិស្ឋាននិងរង់ចាំព្រះអម្ចាស់ឆ្លើយតបដោយអត់ធ្មត់ (ប្រៀបធៀប បរិទេវ ៣:២៥-៣៣)។ មនុស្សដែលនៅដោយឥតកង្វល់និងមនុស្សឆ្មើងឆ្មៃនៅក្នុងខ.៤ ជារឿយៗគឺជាមនុស្សដែលមានអំណាចទទួលបានអ្វីដែលពួកចង់បាន។ ដូច្នេះ អ្នកនិពន្ធសំឡឹងទៅឯអំណាចដែលខ្ពស់ជាងគឺជាព្រះដែលគង់នៅស្ថានសួគ៌សំរាប់ជំនួយនិងសេចក្តីមេត្តាករុណាពីមនុស្សនៅដោយឥតកង្វល់និងឆ្មើងឆ្មៃទាំងនេះ។ សំរាប់រឿងប្រវត្តិសាស្ត្រដែលបង្ហាញអំពីសេចក្តីមើលងាយនិងសេចក្តីចំអកពីមនុស្សនៅដោយឥតកង្វល់និងឆ្មើងឆ្មៃ រួមជាមួយនឹងសេចក្តីជំនឿលើព្រះនៃស្ថានសួគ៌ សូមមើលនេហេមា ២:១៧-២០, ៤:១-៦។ នៅក្នុងរឿងនេះ ប្រជារាស្ត្ររបស់ព្រះជួបប្រទះការប្រឆាំងជំទាស់ជាខ្លាំង ប៉ុន្តែពួកគេបន្តកាតព្វកិច្ចដែលព្រះបានប្រទានឲ្យពួកគេដោយស្មោះត្រង់និងអត់ធ្មត់ ហើយងើបភ្នែកទៅឯព្រះដោយសេចក្តីអធិស្ឋាន។

**ការអនុវត្ត**

ម្តងទៀត ទំនុកដំកើងរំលឹកយើងថា ជីវិតសំរាប់ប្រជារាស្ត្ររបស់ព្រះនៅក្នុងលោកិយនេះគឺមិនងាយស្រួលនោះទេ ហើយយើងមានពួកខ្មាំងសត្រូវដែលចំអកឲ្យយើង ឯព្រះយេស៊ូវបានព្រមានថា ពួកអ្នកដើរតាមទ្រង់នឹងជួបប្រទះសេចក្តីចំអកនិងសេចក្តីមើលងាយដូចគ្នា (ម៉ាថាយ ៥:១០-១២)។ ការឆ្លើយតបត្រឹមត្រូវចំពោះស្ថានភាពទាំងនេះគឺត្រូវតែសំឡឹងទៅឯព្រះដោយសេចក្តីអធិស្ឋាន ពីព្រោះទ្រង់គ្រប់គ្រងលើទាំងអស់ហើយស្រលាញ់ប្រជារាស្ត្ររបស់ទ្រង់។ ដូចដែលអ្នកនិពន្ធស៊ូទ្រាំដើរតាមព្រះយ៉ាងស្មោះត្រង់ហើយមិនបាន

ចូលរួមជាមួយមនុស្សចំអកនៅពេលគាត់បានជួបប្រទះការគៀបសង្កត់ពីអស់អ្នកដែលបង្ហាញសេចក្តីមើលងាយ នោះយើងក៏ត្រូវតែស៊ូទ្រាំដោយអត់ធ្មត់នៅពេលយើងជួបប្រទះការប្រឆាំងជំទាស់ផងដែរ។ នៅពេលអ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបានកំពុងលើកទឹកចិត្តពួកគ្រីស្ទបរិស័ទឲ្យស៊ូទ្រាំនៅក្នុងការជួបប្រទះការប្រឆាំងជំទាស់ គាត់ក៏លើកទឹកចិត្តយើងឲ្យមើលពីគំរូរបស់ព្រះគ្រីស្ទនៅពេលដែលទ្រង់បានយាងទៅឯឈើឆ្កាងផងដែរ(សូមមើលហេព្រើរ ១២:១-៣)។

### Bibliography


Carson, D.A., R. T. France, J. A. Motyer & G. J. Wenham, Ed. (1994), *New Bible commentary: 21st century edition*, (4th ed.) Leicester, England; Downers Grove, IL: Inter-Varsity Press.

Henry, M. (1994), *Matthew Henry's commentary on the whole Bible: Complete and unabridged in one volume*, Peabody: Hendrickson.

Kidner, D. (1975). *Vol. 16*: *Psalms 73–150: An Introduction and Commentary*. Tyndale Old Testament Commentaries. Nottingham, England: Inter-Varsity Press.

Wilcock, Michael. (2001), *The Message of Psalms 73-150.* The Bible Speaks Today Commentaries. Leicester, England: Inter-Varsity Press.